# ការចែករំលែក
# ពីការវិនិយោគនៅកម្ពុជា

ថ្ងៃសៅរ៍ ទី១៩ ខែធ្នូ ឆ្នាំ២០២០
ទីតាំង៖ ផ្ទះស្ងួត្រ និងតាមប្រព័ន្ធអនឡាញ
ពេលវេលា៖ ១៤:00 ដល់ ១៧:00



កម្មវិធីការចែករំលែកពីវិនិយោគនៅកម្ពុជា ជាវេទិកាចែករំលែកមួយ ដែលត្រូវបានសហរៀបចំឡើងដោយ*អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ* និង *កម្មវិធីផ្តោតលើលោកខាងត្បូង* ក្នុងគោលបំណងពង្រឹងចំណេះដឹង និងធ្វើការវិភាគជុំវិញការវិនិយោគនៅក្នុងប្រទេសកម្ពុជា។ អ្នកចូលរួមក្នុងកម្មវិធីនេះរួមមានយុវជន និស្សិត សកម្មជន និងអង្គការសង្គមស៊ីវិល។

កម្មវិធីបានចាប់ផ្តើមជាមួយសំណួរបំផុស ដែលនេះជាវិធីមួយដើម្បីស្ទង់ពីកម្រិតនៃការយល់ដឹងរបស់អ្នកចូលរួម។ សំណួរបំផុសទាំងនោះ ទាក់ទងជាមួយការឱ្យនិយមន័យវិនិយោគ និងការកំណត់គុណសម្បត្តិ និងគុណវិបត្តិរបស់វា។ ការកំណត់និយមន័យនៃការវិនិយោគត្រូវបានឡើងស្រដៀងគ្នាដោយក្នុងនោះរួមមានជាការដាក់ទុន ពេលវេលា និងកម្លាំងក្នុងការកែច្នៃអ្វីមួយ ដើម្បីទទួលបានប្រាក់ចំណេញ ឬ ដើម្បីផលប្រយោជន៍ ឬ ភាពរីកចម្រើនជាដើម។ បើនិយាយពីគុណសម្បត្តិរបស់វិនិយោគ នោះគឺការបង្កើតប្រាក់ចំណេញ ការបង្កើតការងារ កាត់បន្ថយភាពក្រីក្រជាជំនួយដល់សេដ្ឋកិច្ច បង្កើនទំនើបភាព និងមានភាពងាយស្រួល។ ឯគុណវិបត្តិវិញ គឺរួមមានហានិភ័យផ្សេងៗ ការរំលោភបំពានលើសិទ្ធិមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម គំរាមគំហែងដល់ធម្មជាតិ បរិស្ថាន ដល់ការរស់នៅរបស់ប្រជាជន ការបាត់បង់ដីធ្លី និងបង្កើនបំណុលជាដើម។ អ្វីដែលពិសេសនោះគឺ អ្នកចូលរួមចោទជាសំណួរមកវិញថា ដើម្បីចូលរួមផ្តល់និយមន័យ និងផលប៉ះពាល់របស់វិនិយោគឲ្យកាន់តែច្បាស់ ពីព្រោះការវិនិយោគនីមួយៗ មិនដូចគ្នាទាំងស្រុងនោះទេ។ ការចោទសួរមកវិញមានដូចជា ការផ្តល់ការចំណេញដល់អ្នកណាខ្លះ? មានប្រភេទ វិនិយោគអ្វីខ្លះ? យន្តការផ្សេងៗដើម្បីសម្របសម្រួលវិនិយោគ និងការគោរពច្បាប់របស់អ្នកវិនិយោគជាដើម? សំណួរទាំងនេះ ត្រូវបានយកមកឆ្លើយឆ្លងគ្នាក្នុងវគ្គចែករំលែក ដែលជារបៀបវារៈបន្ទាប់ពីកិច្ចស្វាគមន៍ និងការសួរសំណួរបំផុសគំនិត។



វគ្គចែករំលែកនេះត្រូវបានដឹកនាំចែករំលែកដោយ កញ្ញា*រស់ សុគន្ធី* ដែលជាប្រធាន*កម្មវិធីផ្តោតលើពិភពលោកខាងត្បូង*។ វគ្គចែករំលែក បានផ្តោតទៅលើនិយមន័យវិនិយោគ គុណសម្បត្តិនិងគុណវិបត្តិ ការចែងចងច្បាប់ គោលជំហរបស់រដ្ឋាភិបាលក្នុងការវិនិយោគ ការលើកទឹកចិត្តឲ្យមានការវិនិយោគ ប្រភេទនៃវិនិយោគ ដោយភ្ជាប់ជាមួយឧទាហរណ៍នៃការវិនិយោគជាច្រើន ដែលក្នុងនោះមានការវិនិយោគពីអ្នក  វិនិយោគពីប្រទេសជប៉ុននៅកម្ពុជាផងដែរ។ នៅក្នុងចន្លោះចំណុចនីមួយៗនៃការចែករំលែក អ្នកចែករំលែកតែងតែបញ្ចូលសំនួរ ក៏ដូចជាការប្រៀបធៀបខ្លះ ដើម្បីជាជំនួយដល់ការគិតរបស់អ្នកចូលរួម។ សំណួរនោះគឺមានដូចជាតើការចិញ្ចឹមកូនជាការវិនិយោគដែរឬទេ? ចុះការធ្វើរបរលក់បាយ ឬ នំចំណើជាការ វិនិយោគឬក៏អត់? អ្នកចូលរួមបានឆ្លើយយ៉ាងស្រុះគ្នាថាទាំងនោះជាការវិនិយោគ ហើយបានបន្តពន្យល់ថាហេតុអ្វីបានជាការចិញ្ចឹមកូន និងលក់បាយ ឬ នំជាការវិនិយោគ។ មិនត្រឹមតែប៉ុណ្ណោះ អំឡុងពេលចែករំលែក ក៏មានការចូលរួមជាសំណួរ មតិ និងទស្សនៈដែលទាក់ទងនឹងកិច្ចពិភាក្សានេះពីអ្នកចូលរួម។

បើទោះបីជាការសួរសំណួរត្រូវបានបើកឲ្យមានតាំងពីដើមកម្មវិធី សំណួរនៅតែមានជាបន្តបន្ទាប់ក្នុងវគ្គសួរសំណួរ។ អ្នកចូលរួមបានសួរសំណួរដែលស៊ីជម្រៅទាក់ទងជាមួយតួនាទីរដ្ឋាភិបាល ការប្រើប្រាស់នយោបាយក្នុងការវិនិយោគ ការប្រៀបធៀបទៅនឹងប្រទេសជិតខាងយន្តការរបស់រដ្ឋាភិបាលនិងការវិនិយោគបែបណាដែលប្រទេសយើងគួរអភិវឌ្ឍ។ ពីសំណួរមួយទៅសំណួរមួយទៀត អ្នកចែករំលែកបានផ្តល់ចម្លើយដែលបានបង្កប់អត្ថន័យ ក្នុងគោលបំណងទាញការគិតរបស់អ្នកចូលរួម ថាតើខ្លួនអាចធ្វើអ្វីខ្លះបានក្នុងរបត់នៃការវិនិយោគនេះ?តើអ្វីដែលល្អសម្រាប់ការលូតលាស់នៃប្រទេសជាតិ? ហើយអ្នកចូលរួមផ្សេងទៀត ក៏ដូចគ្នាដែរបានចូលយ៉ាងសកម្មក្នុងការផ្តល់មតិ យោបល់ និងព័ត៌មានផ្សេងៗទៅកាន់អ្នកចែករំលែក។

យ៉ាងណាមិញ យើងក៏គួរតែកត់សំគាល់ដែរថា កម្មវិធីប្រព្រឹត្តតាមប្រព័ន្ធអនឡាញ និងកម្មវិធីផ្ទាល់ ហើយនេះជាបទពិសោធន៍ដែលថ្មីសម្រាប់អ្នកដែលបានចូលរួមតាមប្រព័ន្ធអនឡាញ និងអ្នករៀបចំកម្មវិធីផងដែរ។ ជាក្តីសារទរមួយសម្រាប់អ្នករៀបចំកម្មវិធី ដោយបានឃើញការចូលរួមយ៉ាងសកម្ម និងកម្រិតខ្ពស់នៃការយល់ដឹងរបស់អ្នកចូលរួមទៅលើការវិនិយោគនៅកម្ពុជា។ ជាងនេះទៅទៀត សកម្មភាពនៃការសរសេរចុះរបស់អ្នកចូលរួមបានបង្ហាញពីការយកចិត្តទុកដាក់ ហើយនឹងការបានរៀនអ្វីថ្មីៗ ពីការចែករំលែកនេះ គឺជាក្តីរីករាយមួយទៀត។

គួរបញ្ជាក់ផងថា កម្មវិធីចែករំលែកដែលប្រព្រឹត្តទៅនៅ ថ្ងៃទី១៩ គឺគ្រាន់ជាវគ្គដំបូងប៉ុណ្ណោះ។ ការបង្កើតឡើងនៃវ គ្គនេះ គឺដើម្បីពង្រឹងចំណេះដឹងមូលដ្ឋានដល់អ្នកចូលរួមគោលដៅ។ វគ្គបន្តបន្ទាប់នៃការចែករំលែកនេះនឹងត្រូវធ្វើឡើងក្រោមប្រធានបទដដែលតែមានភាពស៊ីជម្រៅជាងមុន។

អំពីអ្នករៀបរៀងអត្ថបទ៖ កញ្ញា *នន់ លីណា* ជានិស្សិតស្ម័គ្រចិត្ត រយៈពេលប្រាំមួយខែ នៅ*អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ*។ នាងមានតួនាទីជាជំនួយការកម្មវិធី ហើយបានចូលរួមជាមួយក្រុមកាងារ *សកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ* ចាប់ពីខែកក្កដា ឆ្នាំ២០២០។ *លីណា* ជានិស្សិតមហាវិទ្យាល័យ ទំនាក់ទំនងអន្តរជាតិនៃ*សកលវិទ្យាល័យភូមិន្ទភ្នំពេញ*។




**Contact Detail**

**Mobile:** (+855) 17 454 535
**Email:** chreksophea@gmail.com
**Website:** https://sac.unitedsisterhood.org/
**Facebook:** Social Action for Community and Development